# ក

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 13 ខែ 06 ឆ្នាំ 2013

## មាតិកា

### ខុទ្ទកាល័យព្រះមហាក្សត្រ


| | | |
|---|---|---|
| ១៦-១១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៣៤ ស្ដីពីការតែងតាំងឯក ឧត្តម **សុភក្ដិ ធីថៅ** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា | ៣០០៨ |
| ១៧-១១-២០០១ | - ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៣៥ ស្ដីពីការតែងតាំងឯកឧត្តម **ប្រាក់ ឡេង** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា | ៣០០៩ |
| ១៩-១១-២០០១ | - ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៣៦ ស្ដីពីការតែងតាំង លោក **ថោង សារ៉ាត់** ជា **ឧកញ៉ា** | ៣០១០ |
| ២០-១១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៣៧ ស្ដីពីការតែងតាំងឯក ឧត្តម **គុំ សារ៉ុន** ជាទីប្រឹក្សាសម្ដេច **ហេង សំរិន** អនុប្រធានទី ១ រដ្ឋសភា ទទួលបន្ទុកកសិកម្ម | ៣០១១ |
| ២១-១១-២០០១ | - ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៣៨ ស្ដីពីការតែងតាំងឯក ឧត្តម **អ៊ុច ថោងសេង** ជាសមាជិក នៃអាជ្ញាធរអគ្គិសនីកម្ពុជា | ៣០១២ |
| ២២-១១-២០០១ | - ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៣៩ ស្ដីពីការបំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ជូនឯកឧត្តមអនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្នាដៃនិងគុណបំណាច់ដ៏ឧត្តុង្គឧត្តមក្នុងការរៀបចំការ បោះឆ្នោតរួមចំណែកយ៉ាងសកម្មក្នុងការផ្សះផ្សាបង្រួបបង្រួមជាតិ | ៣០១៣ |
| ២២-១១-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/១១០១/៤៤០ ស្ដីពីការ បំពាក់គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់មាស ០១ គ្រឿង ប្រាក់ ០១គ្រឿង និង សំរិទ្ធ ០១ គ្រឿង ជូនដល់:<br>១- អង្គភាពវរសេនាតូចលេខ២ ចំណុះនាយកដ្ឋាននគរបាលព្រំដែនទឹក<br>២- លោក អនុសេនីយ៍ឯក **តេង សួង** មេបញ្ជាការវរសេនាតូចលេខ ២ | ៣០១៥ |


## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


| | | |
|---|---|---|
| ២១-១១-២០០១ | - អនុក្រឹត្យ លេខ ១១៥ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មាធិការជាតិ សំរបសំរួល ការដឹកជញ្ជូនឆ្លងកាត់ | ៣០១៦ |
| ១៦-១១-២០០១ | -អនុក្រឹត្យ លេខ ៤៧៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៣០២១ |
| ១៦-១១-២០០១ | -អនុក្រឹត្យ លេខ ៤៧៤ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៣០២២ |

១៦-១១-២០០១ -អនុក្រឹត្យ លេខ ៤៧៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣០២៤

១៩-១១-២០០១ -អនុក្រឹត្យ លេខ ៤៧៦ អនក្រ.តត ស្ដីពីការតែងតាំងនិងផ្លាស់ប្ដូរភារកិច្ច ៣០២៦

២០-១១-២០០១ -អនុក្រឹត្យ លេខ ៤៧៧ អនក្រ.តត ស្ដីពីការតម្លើងឋានៈនាយនគរបាលជាតិ ៣០២៨

២០-១១-២០០១ -អនុក្រឹត្យ លេខ ៤៧៨ អនក្រ.តត ស្ដីពីការតម្លើងឋានៈនាយនគរបាលជាតិ ៣០២៩

២០-១១-២០០១ -អនុក្រឹត្យ លេខ ៤៧៩ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៣០៣០

២០-១១-២០០១ -អនុក្រឹត្យ លេខ ៤៨០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣០៣១

២០-២-១១-២០០១ -អនុក្រឹត្យ លេខ ៤៨១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣០៣២

២២-១១-២០០១ -អនុក្រឹត្យ លេខ ៤៨២ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៣០៣៣

២៣-១១-២០០១ -អនុក្រឹត្យ លេខ ៤៨៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣០៤២

២៣-១១-២០០១ -អនុក្រឹត្យ លេខ ៤៨៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣០៤៣

២៣-១១-២០០១ -អនុក្រឹត្យ លេខ ៤៨៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣០៤៥

២០-១១-២០០១ -អនុក្រឹត្យ លេខ ៤៨៦ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៣០៤៦

### ២~ បទបញ្ជា

២០-១១-២០០១ - លិខិតបញ្ជា លេខ ០១ បប របស់រាជរដ្ឋាភិបាល ៣០៤៧

## III-ការងារបណ្ដាក្រសួង

### ១~ ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៩-១១-២០០១ -ប្រកាសលេខ ៣១៤ MoC/M 2001 ស្ដីពីស្ថានភាពរោងចក្រកាត់ដេរមួយចំនួន ៣០៤៨

### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

២០-១១-២០០១ -ប្រកាសលេខ ៧២៦ ឧរថកឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាយដ៍ ខូត ធីប៉ែកខូ ខូ អិលធីឌី (WIDE CODE TOBACCO.,LTD.) តំណាងដោយលោក LIANG GUOHA សញ្ជាតិចិន បង្កើតរោងចក្រ "ផលិតបារី" ដែលមានឈ្មោះថា "វ៉ាយដ៍ ខូត ធីប៉ែកខូ" មានទីតាំងស្ថិតនៅភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ៣០៥០

### ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

១៦-១១-២០០១ -សារាចរណែនាំលេខ ៣៩៩ សរណ ធទឧ ស្ដីពីវិធានការទប់ទល់គ្រោះ រាំងស្ងួតក្នុងរដូវវស្សា និងត្រៀមលក្ខណៈសំរាប់ស្រូវប្រដេញទឹក និងស្រូវប្រាំង ឆ្នាំ ២០០១-២០០២ ៣០៥២

១៦-១១-២០០១ ### ៤~ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-ប្រកាសលេខ ៨០៧ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះវិទ្យាល័យ "ស្រុកបាត់ដំបង"

| | | |
|---|---|---|
| | ទៅជាវិទ្យាល័យ"ថ្មគោល" ស្ថិតនៅស្រុក ថ្មគោល ខេត្ត បាត់ដំបង | ៣០៥៤ |
| ១៦-១១-២០០១ | -ប្រកាសលេខ ៨០៨ អយក.ប្រក ស្តីពីការពង្រីក អនុវិទ្យាល័យ"សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិមហាលាភ " ទៅជាវិទ្យាល័យ " សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ មហាលាភ " ស្ថិតនៅក្នុងឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម | ៣០៥៥ |
| ១៦-១១-២០០១ | -ប្រកាសលេខ ៨០៩ អយក.ប្រក ស្តីពីការពង្រីក អនុវិទ្យាល័យ"តាមាង" ទៅជាវិទ្យាល័យ "តាមាង" ស្ថិតនៅក្នុងឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម | ៣០៥៦ |

### ៥.ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

| | | |
|---|---|---|
| ២២-១១-២០០១ | - ប្រកាសលេខ ៣០៥ សកបយ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករ និយោជិត នៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចា ជាសមូហភាពដើម្បីចុះ អនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន | ៣០៥៧ |

### ៦.ទីស្តីការរដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា

| | | |
|---|---|---|
| ១៩-១១-២០០១ | - សេចក្តីសំរេចលេខ ២៩៩ កធស សរ ស្តីពីការអនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ " ក្សត្រីសន្តិភាព " មួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល | ៣០៦៦ |
| ១៩-១១-២០០១ | - សេចក្តីសំរេចលេខ ៣០០កធស សរ ស្តីពីការអនុញ្ញាតឱ្យ បើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ"សេវេនដេយអាត់វេនទីស្ទព្រះគោថ្មី" មួយកន្លែងដែល មានទី តាំងស្ថិតនៅក្រុមទី១ ភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប | ៣០៦៨ |

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៣៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៧៦២ រស ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំងឯកឧត្តម សុគុណៈ នីឆៅ ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០១

ពរល-០១-១១-០០៣៦

លេខៈ ៥៨៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០១

រដ្ឋលេខាធិការរាជរដ្ឋាភិបាល

ស៊ាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៣៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៧៦០ រស ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០១

**ត្រាស់បង្គាប់**

**មាត្រា១.-** តែងតាំងឯកឧត្តម **ឡោត ខៀង** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២.-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០០១

តរស-០១-១១.០០៣២

លេខ: ២៨៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[signature]

... តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៣៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ថោង សារ៉ាត់

ជា

ឧកញ៉ា

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ២៨៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០០១

៣៨_០១_១១_០០៣០

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៣៧

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ
រាជរាជវង្ស ឧត្តមគោរព្យជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលស៊ើសុំរបស់សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៧៧៦ រស ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០០១

ត្រាស់បង្គាប់

មាត្រា១ .- តែងតាំងឯកឧត្តម គុំ សារ៉ុន ជាទីប្រឹក្សា សម្ដេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា ទទួលបន្ទុកវិស័យកសិកម្ម មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ:២៨៥ ច.ល

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០០១

៣៤៨.០១.១១.០០៣៣

ចម្លងចែកជូន

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៣៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម អ៊ិច ថៅនសេង ជាសមាជិក នៃអាជ្ញាធរអគ្គិសនីកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ វិច្ឆិកា ឆ្នាំ ២០០១*

ពរល-០១-១១-០០៣៤

លេខ ៧៩៤ ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឯកអ៊ី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៣៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រសេ/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ជូនឯកឧត្តមអនុប្រធាន និង សមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានស្នាដៃ និងគុណបំណាច់ដ៏ឧត្តុង្គឧត្តម ក្នុងការរៀបចំការបោះឆ្នោត រួមចំណែកយ៉ាងសកម្ម ក្នុងការផ្សះផ្សាបង្រួបបង្រួមជាតិ ដូចមានរាយនាមខាងក្រោម :

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា :

- ឯកឧត្តម **នៅ ភាស៊ី** អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១ - ឯកឧត្តម **ដូ កុងឌួន** សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

២ - ឯកឧត្តម **រាយ គីម** សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៣ - ឯកឧត្តម **យូ ភន** សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៤ - ឯកឧត្តម **ទិព្វ ច័ន្ទវិបុល** សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៥ - ឯកឧត្តម **អ៊ីង គីមអេង** សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៦ - ឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៧ - ឯកឧត្តម **ជា ចំរើន** សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាស- ០១- ១១- ០០៣៥

លេខ: ២៨៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៤០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : បំពាក់មេដាយ ការពារជាតិ ថ្នាក់មាស ០១ គ្រឿង ប្រាក់ ០១ គ្រឿង និង សំរិទ្ធ ០១ គ្រឿង ជូនដល់ :

១- អង្គភាពវរសេនាតូចលេខ ២ ចំណុះនាយកដ្ឋាន នគរបាលព្រំដែនទឹក

២- លោកអនុសេនីយ៍ឯក គេង សួន មេបញ្ជាការវរសេនាតូចលេខ ២

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៧៩៥ ច.ល

ច្បាប់ចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០១

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១

៣៩៧-០២-១១-០០៣៦

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ...១១៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់

*****

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញ អនុក្រឹត្យលេខ ១៤អនក្រ.ស.ក ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

## សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការបង្កើតគណៈកម្មាធិការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ ដើម្បីសំរបសំរួលតាមដានត្រួតពិនិត្យ ឱ្យមានប្រសិទ្ធិភាព លើការដឹកជញ្ជូនឆ្លងកាត់ជាទូទៅរវាង ប្រទេសដែលជាសមាជិកអាស៊ាន និងប្រទេសនានា ដែលមានកិច្ចព្រមព្រៀងទ្វេរភាគី ឬ ពហុភាគី ជាមួយព្រះរាជាណាចក្រកម្ពុជា ស្តីពីការសំរួលការដឹកជញ្ជូនឆ្លងកាត់ ។

ការដឹកជញ្ជូនឆ្លងកាត់ មានន័យថាជាការដឹកជញ្ជូនទំនិញ និងអ្នកដំណើរ ចូល ចេញ ឬឆ្លងកាត់ព្រំដែនទឹកដីនៃប្រទេសមួយ។

មាត្រា ២.-

គណៈកម្មាធិការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ ហៅកាត់ថា គជសជឆ ដែលសរសេរជាភាសាអង់គ្លេស ហៅថា National Transit Transport Coordinating Committee ដែលសរសេរកាត់ថា NTTCC ។

## ជំពូកទី ២
## ផ្នែកទី១
## សមាសភាព

មាត្រា ៣.-

គជសជឆ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- អគ្គនាយក នៃក្រសួងសាធារណការ និងដឹកជញ្ជូន | ជាប្រធាន |
| ២- អគ្គនាយករង នៃក្រសួងពាណិជ្ជកម្ម | ជាអនុប្រធាន |
| ៣- អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៤- អគ្គនាយករងអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាអនុប្រធាន |
| ៥- ប្រធាន លេខាធិការដ្ឋានបច្ចេកទេស | ជាសមាជិកអចិន្ត្រៃយ៍ |
| ៦- តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៧- តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| ៨- តំណាងក្រសួងសុខាភិបាល | ជាសមាជិក |
| ៩- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ១០- តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ជាសមាជិក |
| ១១- តំណាងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| ១២- តំណាងទីចាត់ការគយ និងរដ្ឋាករ | ជាសមាជិក |
| ១៣- តំណាងសភាពាណិជ្ជកម្ម | ជាសមាជិក |
| ១៤- តំណាងសមាគមជាតិ នៃអ្នកធ្វើសេវាបញ្ជូនទំនិញ | ជាសមាជិក |
| ១៥- តំណាងសមាគមជាតិ នៃអ្នកប្រើប្រាស់ការដឹកជញ្ជូនជាម្ចាស់ទំនិញ | ជាសមាជិក |
| ១៦- តំណាងសមាគមជាតិ នៃអ្នកផ្តល់មធ្យោបាយដឹកជញ្ជូន | ជាសមាជិក |
| ១៧- តំណាងសមាគមជាតិ នៃក្រុមហ៊ុនធានារ៉ាប់រង | ជាសមាជិក |
| ១៨- តំណាងសមាគមជាតិ នៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ | ជាសមាជិក |

សមាសភាពជាតំណាងក្រសួង ឬស្ថាប័ន ត្រូវអោយមានជំនាញពាក់ព័ន្ធកិច្ចការដឹកជញ្ជូនឆ្លងកាត់ និងមានសមត្ថកិច្ចជំនួសអោយក្រសួងស្ថាប័នរបស់ខ្លួន លើសេចក្តីសំរេចផ្សេងៗជាការចាំបាច់ ។

## ផ្នែកទី២
## តួនាទី ភារកិច្ច

មាត្រា ៤.-

គជសជឆ មានតួនាទី និងភារកិច្ចដូចតទៅ :

- ពិគ្រោះ ពិភាក្សា ផ្តល់យោបល់ ចាត់ចែង និងសំរបសំរួល រវាងស្ថាប័នជាតិមានសមត្ថកិច្ច និងស្ថាប័នទាំងឡាយដែលពាក់ព័ន្ធ លើការងារដឹកជញ្ជូនឆ្លងកាត់ និងពាណិជ្ជកម្មអន្តរជាតិ
- ទទួលខុសត្រូវក្នុងការកាត់បន្ថយ និងសំរួលបែបបទអោយស៊ីសង្វាក់គ្នា ឬធ្វើអោយមានទំនើបកម្ម នៃការដឹកជញ្ជូនឆ្លងកាត់ ការធ្វើពាណិជ្ជកម្ម បច្ចេកវិទ្យា តាមរយៈការស្នើអោយកែលំអបទប្បញ្ញត្តិនិងនីតិវិធី ដែលមានជាធរមាន

អោយសមស្របទៅនឹងគោលការណ៍និងទិសដៅ នៃកិច្ចព្រមព្រៀងជាក្របខំណ្ឌ

- រៀបចំរនុសាសន៍ កម្មវិធី គោលនយោបាយ ឯកសារទាំងឡាយដែលប្រើប្រាស់ និងទ្រទ្រង់ក្នុងការអនុវត្តន៍ ការដឹកជញ្ជូនឆ្លងកាត់ និងពាណិជ្ជកម្មអន្តរជាតិ នៃបណ្តាប្រទេសជាសមាជិកអាស៊ាន និងប្រទេសក្នុងតំបន់ផ្សេងទៀត
- ទំនាក់ទំនង ព្រមទាំងធ្វើសហប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ និងពាណិជ្ជកម្មអន្តរជាតិនៃបណ្តាប្រទេស ជាសមាជិកអាស៊ាន និងប្រទេសក្នុងតំបន់ផ្សេងទៀត
- រៀបចំចុះបញ្ជី និងផ្តល់បណ្ណអនុញ្ញាត ជូនអ្នកធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់
- ប្រមូលផ្តុំចងក្រង ពត៌មាន ស្ថិតិទិន្នន័យ ព្រមទាំងជំរុញការអនុម័ត ការដាក់ចេញអោយប្រើប្រាស់បទដ្ឋាន និងស្តង់ដារ ដែលមានការទទួលស្គាល់ជាអន្តរជាតិ សំរាប់កិច្ចការជំនួញ ពាណិជ្ជកម្មអន្តរជាតិ ប្រតិបត្តិការ និងសេវាកម្មដឹកជញ្ជូនឆ្លងកាត់
- វាយតំលៃផលប្រយោជន៍ជាតិទាក់ទងទៅនឹងការទទួល ព្រមទាំងការអនុវត្តន៍អនុសញ្ញាអន្តរជាតិ ដែលសំរួលការដឹកជញ្ជូនឆ្លងកាត់ និងការធ្វើពាណិជ្ជកម្ម
- បង្កើនការយល់ដឹង ទទួលយកនូវការអនុវត្តន៍វិធីសាស្ត្រ និងអត្ថប្រយោជន៍នានា ពាក់ព័ន្ធនឹងការដឹកជញ្ជូនឆ្លងកាត់ ទាំងផ្នែកឯកជន ទាំងផ្នែកសាធារណៈ តាមរយៈកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំពិភាក្សា ផ្សព្វផ្សាយ និងទស្សនកិច្ចសិក្សា
- កំណត់ភាគទាន ឬវិភាគទាន និងជំនួយឧបត្ថម្ភផ្សេងៗ ដើម្បីទ្រទ្រង់ដល់ដំណើរការការងាររបស់ គជសជឆ
- ធ្វើរបាយការណ៍ជាប្រចាំ អំពីដំណើរការនិងសកម្មភាពអនុវត្តការងាររបស់ គជសជឆ ជូនរាជរដ្ឋាភិបាល និងស្ថាប័នជាតិ និងអន្តរជាតិពាក់ព័ន្ធ
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុ ស្តីពីតំរោងថវិកា និង ចំណូល ចំណាយប្រចាំឆ្នាំរបស់ គជសជឆ ដោយអនុលោមទៅតាមច្បាប់ហិរញ្ញវត្ថុ ។

មាត្រា ៥ .-

គជសជឆ នេះ មាននាទី ជាភ្នាក់ងារប្រឹក្សា ផ្តល់យោបល់ និងសំរបសំរួលក្នុងសមត្ថកិច្ចរបស់ខ្លួនរវាង ក្រសួង-ស្ថាប័នទាំងឡាយ ។

សេចក្តីសំរេចរបស់ គជសជឆ អាចចាត់ទុកជាសេចក្តីសំរេចផ្លូវការ របស់ក្រសួង-ស្ថាប័នទាំងឡាយរបស់រាជរដ្ឋាភិបាល ដែលមានតំណាងចូលរួមជាសមាជិក នៅក្នុង គជសជឆ ។

មាត្រា ៦ .-

គជសជឆ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញឬ អ្នកឯកទេសអោយចូលរួមប្រជុំ ពិគ្រោះពិភាក្សា ផ្តល់យោបល់ និងសិក្សាស្រាវជ្រាវ រាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន ។

មាត្រា ៧ .-

គជសជឆ ត្រូវជួបប្រជុំដោយទៀងទាត់ តាមការអញ្ជើញរបស់ប្រធាន ។

មាត្រា ៨ .-

គជសជឆ ត្រូវរៀបចំបង្កើតបែបបទ នីតិវិធីធ្វើការងារ និងបទបញ្ជាផ្ទៃក្នុង ។

## ផ្នែកទី៣
## លេខាធិការដ្ឋានបច្ចេកទេស

មាត្រា ៩.-

គជសជឆ ត្រូវបានទទួលការអនុញ្ញាត អោយប្រើប្រាស់លេខាធិការដ្ឋានបច្ចេកទេសមួយ ដែលមានទីតាំងនៅទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ១០.-

បុគ្គលិកដែលបំរើការងារនៅលេខាធិការដ្ឋាននេះ ត្រូវជ្រើសតាំងក្នុងចំណោម មន្ត្រីក្របខ័ណ្ឌរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ១១.-

លេខាធិការដ្ឋានបច្ចេកទេស ត្រូវដឹកនាំដោយមន្ត្រីក្របខ័ណ្ឌមួយរូបជាប្រធាន ដែលមានឋានៈថ្នាក់នាយកដ្ឋាន និងមានអនុប្រធានមួយរូប ឬច្រើនរូប តាមការចាំបាច់ ដែលត្រូវជ្រើសរើសតាមសំណើរបស់ប្រធាន និងដោយមានការយល់ព្រមពីសមាជិក គជសជឆ ។

មាត្រា ១២.-

លេខាធិការដ្ឋាននេះ មានភារកិច្ចដូចតទៅ :

- ជួយការងារ របស់ គជសជឆ ក្នុងការសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់
- រៀបចំកម្មវិធី ខ្លឹមសារ និងរបៀបវារៈសំរាប់អង្គប្រជុំនៃ គជសជឆ និងសកម្មភាពផ្សេងៗ ដូចជាការអភិវឌ្ឍន៍ធនធានមនុស្សជាដើម
- ជំរុញ និងតាមដានការអនុវត្តន៍សេចក្តីសំរេចរបស់ គជសជឆ ក៏ដូចជាការអនុវត្តន៍ កិច្ចព្រមព្រៀងទាំងឡាយ និងការសំរួល ការដឹកជញ្ជូនឆ្លងកាត់
- សិក្សាស្រាវជ្រាវ និងលើកឡើង នូវវិធានការចាំបាច់នានា និងធ្វើរបាយការណ៍តាមកាលកំណត់ សំរាប់ជូន គជសជឆ និងស្ថាប័នជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ
- ប្រមូលផ្តុំ ចងក្រង ចំលង និងផ្សព្វផ្សាយឯកសារជូនគ្រប់ក្រសួង ស្ថាប័ននានា លើការងារពាក់ព័ន្ធ
- រៀបចំគំរោងថវិកាប្រចាំឆ្នាំ របស់ គជសជឆ
- ការងារផ្សេងៗទៀត ដែល គជសជឆ ប្រគល់អោយ ។

## ជំពូកទី ៣
## ថវិការបស់គណៈកម្មាធិការជាតិ

មាត្រា ១៣.-

គជសជឆ ត្រូវរៀបចំអោយមានថវិកាដោយឡែករបស់ខ្លួន ដើម្បីធានា អោយមានប្រសិទ្ធភាពជានិរន្តរ៍ នូវកិច្ចប្រតិបត្តិនិងមុខងារនៃគណៈកម្មាធិការជាតិនេះ ។

មាត្រា ១៤.-

ប្រភពចំណូលថវិកា របស់ គជសជឆ បានមកពី :

- ថវិកាជាតិ សំរាប់ជាការផ្តួចផ្តើមគ្រាដំបូង ការបញ្ជូនភ្នាក់ងារជាសមាជិកចូលរួមកិច្ចប្រជុំ សន្និបាតផ្សេងៗ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_____

និងចំណាយចាំបាច់ផ្សេងៗ ដែលជាឧបសម្ព័ន្ធរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

- ភាគទានពីសមាជិក ហើយភាគទាននេះត្រូវកំណត់ និងអនុម័តដោយ គជសជឆ
- វិភាគទាន និងជំនួយឧបត្ថម្ភផ្សេងៗ ។

មាត្រា ១៥ .-

ក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួន គជសជឆ ត្រូវបានអនុញ្ញាតអោយមានហិរញ្ញិកមួយរូប ឬច្រើនរូបតាមការចាំបាច់ ដើម្បីគ្រប់គ្រង និងធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនគណៈកម្មាធិការជាតិ ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

មាត្រា ១៦ .-

គជសជឆ អាចប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

មាត្រា ១៧ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៨ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពដូចក្នុងមាត្រា៣ និងមាត្រា ១១ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

**សម្តេចនាយករដ្ឋមន្ត្រី**

សូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ឃឹម តាំងលីម

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១៨
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧៣ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនវត្តតាកេហ្វ៊ីជីហ្សូអ៊ីន ( TAKEFU JIZOIN TEMPLE ) នៅប្រទេសជប៉ុន ដែលបានបរិច្ចាគថវិកា ២១.៦៥០.៨ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ នៅឃុំទរាយណី ស្រុកឈូក ខេត្តកំពត ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

## សំរេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសការងារ**ជូនថ្នាក់ដឹកនាំ និងអង្គភាព នៃក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដែលមានស្នាដៃល្អក្នុងការធ្វើអធិការកិច្ចទប់ស្កាត់ការចំណាយថវិការដ្ឋជូនមុខសញ្ញាពលី ពិការ មានភាពមិនប្រក្រតី ដូចមានរាយនាមខាងក្រោមនេះ :

១- លោកជំទាវ **មូរ សុខហួរ** រដ្ឋមន្ត្រី

២- លោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋលេខាធិការ

៣- លោកជំទាវ **យូ អយ** រដ្ឋលេខាធិការ

៤- ឯកឧត្តម **សោម ចន្ទំរ៉ែម** អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម **ឡៀវ ឈាង** អគ្គាធិការ

៦- នាយកដ្ឋាន **សោធនអតីតយុទ្ធជន**

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា ២
-រាជកិច្ច ✓
-កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## សំរេច

**មាត្រា ១** :ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងព្រះវិហារវត្តមេព្រីង ស្ថិតនៅក្នុងឃុំមេព្រីង ស្រុកបាធាយ ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ ÷

១ - ព្រះតេជគុណ **មាឃ សុគ័ណ្ឌ** ចៅអធិការវត្តមេព្រីង បច្ច័យចំនួន : ៣៦.២៩៩ USD

២ - លោក **ថោង សារ៉ាត់** អគ្គនាយកក្រុមហ៊ុនសំណង់ និង អភិវឌ្ឍន៍ ថវិកាចំនួន : ១៣៧.៩៩០ USD

៣ - លោ **កេ អ៊ឹម** និងលោកស្រី **ហាំ សារឿន** ថវិកាចំនួន : ១១.៣២៨ USD

៤ - លោក **ប៊ុន សុផាន្នី** និងលោកស្រី **វ៉េន សារឿន** ថវិកាចំនួន : ១១.២៩៩ USD

៥ - លោក **កែវ សារឥត្ថី** និងលោកស្រី **វ៉ីន ណូយ** ថវិកាចំនួន : ១១.២០០ USD

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៥២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំង និងផ្លាស់ប្តូរភារកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១** : តែងតាំងផ្លាស់ប្តូរភារកិច្ចឯកឧត្តមឧត្តមសេនីយ៍ត្រី គីម ប៊ុនថាន ពីនាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្ន ជានាយករងខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២** : ផ្ទេរក្របខ័ណ្ឌឧត្តមសេនីយ៍ត្រី គីម ប៊ុនថាន ពីក្របខ័ណ្ឌនគរបាលជាតិ នៃក្រសួងមហាផ្ទៃ មកក្នុងក្របខ័ណ្ឌរបស់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ នៃក្រសួងការពារជាតិ ។

**មាត្រា ៣** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកនគរបាលជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៥០១.១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈ ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- បានឃើញព្រះរាជក្រមលេខ ០២ . នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១-លោកវរៈសេនីយ៍ទោ **ហេង សារ៉ាត់** អត្តលេខ ០៥៥៤ អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ ។

២-លោកវរៈសេនីយ៍ទោ **ឈុំ ឆន** អត្តលេខ ០៧២៦ អនុប្រធាននាយកដ្ឋានស្ថាបនា

៣-លោកវរៈសេនីយ៍ទោ **នូ ប៊ុនថា** អត្តលេខ ០៦៩១ អនុប្រធាននាយកដ្ឋានអង្គរក្ស

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤៧៥...អនក្រ - បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ . នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១-លោកវរៈសេនីយ៍ទោ **ខ្វន់ ចន្ធី** អត្តលេខ ០៦១១ អនុប្រធាននាយកដ្ឋានសុខាភិបាល

២-លោកវរៈសេនីយ៍ទោ **សៅ ធីរះឧុយ** អត្តលេខ ០៥៩៨ អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានប្រគល់ **មេដាយការងារ** ថ្នាក់មាស ជូនដល់នាយនគរបាលជាតិចំនួន ០៣រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

១- លោកអនុសេនីយ៍ឯក **តេង សួន** មេបញ្ជាការវរសេនាតូចលេខ ២ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

២- លោកអនុសេនីយ៍ទោ **ស៊ិន ដារ៉ូ** មេបញ្ជាការរង វរសេនាតូចលេខ ២ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

៣- លោកអនុសេនីយ៍ទោ **អឿ ខេង** មេបញ្ជាការរង វរសេនាតូចលេខ ២ នៃនាយកដ្ឋាននគរបាលព្រំដែនទឹក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

*- ក្រសួងព្រះបរមរាជវាំង*
*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*- ដូចមាត្រា ២*
*- ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៧០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/ រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

<u>មាត្រា ១</u> : ត្រូវបានតែងតាំងលោក **ឃិន សុទ្ធិនចិន្តា** ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងនាមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

<u>មាត្រា ២</u> : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

<u>មាត្រា ៣</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>**ចម្លងជូន**</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣ <u>"ដើម្បីអនុវត្ត"</u>*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៤៨១...អនក្រ-បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី MIEKO OSANAI ប្រធានអង្គការ J H P ដែលបានជួយសាងសង់អាគារសិក្សា ២ កន្លែង ចំនួន ៣ខ្នង មាន ១៤ បន្ទប់ ស្ថិតនៅក្នុងសាលាបឋមសិក្សាត្រពាំងក្រសាំង និង សាលាបឋមសិក្សាត្រគៀត ខ័ណ្ឌដង្កោ សរុបទឹកប្រាក់ទាំងអស់ចំនួន ៨៨.៨២៤ USD ។

ប្រការ៩ : អគ្គនាយកឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វ៉ាយដ៏ ខូត ធីប៊ែកខូ ខូអិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀង១ខ្លួន ។

ប្រការ១០ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច-ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និង ឧតុនិយម

លេខ ៣៩៩ ...ធម

# សារាចរណែនាំ

## ស្តីអំពី

## វិធានការទប់ទល់គ្រោះរាំងស្ងួតក្នុងរដូវវស្សា និងត្រៀមលក្ខណៈ សំរាប់ស្រូវប្រដេញទឹក និងស្រូវប្រាំង ឆ្នាំ 2001 – 2002

ក្នុងឆ្នាំ 2001 នេះ ស្ថានភាពអាកាសធាតុមានការប្រែប្រួលខុសប្រក្រតី ទន្ទឹមនេះការគ្រប់គ្រងធនធានទឹក នៅតំបន់ដីសណ្តកម្ពុជា-វៀតណាមពុំបានល្អប្រសើរ ដែលជាហេតុធ្វើឱ្យតំបន់ទំនាបមួយចំនួន នៃព្រះរាជាណាចក្រកម្ពុជាដែលពុំធ្លាប់លិចប្រែក្លាយជាលិច និងតំបន់មួយចំនួនទៀតដែលត្រូវលិចក្នុងរយៈពេលខ្លី បែរជាលិចក្នុងរយៈពេលយូរដោយល្បឿននៃការស្រកយឺត។ ដោយឡែក តំបន់ខ្ពង់រាបមួយចំនួនទៀតបែរជារងគ្រោះដោយការរាំងស្ងួតទៅវិញក្នុងអំឡុងនៃខែកក្កដា ដែលមានរយៈពេលប្រមាណពី 15ថ្ងៃ ទៅ 27ថ្ងៃ។ ការកើតឡើងនៃគ្រោះធម្មជាតិទាំងពីរនេះ បានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាកសិករ ខូចខាតទ្រព្យសម្បត្តិប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាច្រើន។

យោលទៅលើសភាពការណ៍ជាក់ស្តែងខាងលើនេះ ក្រសួងបានចេញសារាចរណែនាំជាបន្តបន្ទាប់រួចហើយ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃវិធានការ ក្រសួងសូមធ្វើការរំលឹកឡើងវិញ និងបន្ថែមនូវការណែនាំមួយចំនួនទៀតជូនដល់គ្រប់មន្ទីរធនធានទឹក និងឧតុនិយមខេត្ត-ក្រុង ដូចខាងក្រោម ÷

1. យកចិត្តទុកដាក់ក្នុងការទប់ភ្លឺស្រែឱ្យបានគត់មត់ និងថែទាំជាប្រចាំដើម្បីរក្សាទឹកទុកក្នុងស្រែឱ្យបានក្នុងកំរិតអតិបរមា ជៀសវាងការខ្វះខាតទឹកទាំងស្រុងនាចុងរដូវវស្សា។

2. ចាត់ចែង និងត្រៀមលក្ខណៈបិទទ្វារទឹកទំនប់អាង ដើម្បីតំកល់ទឹកទុកសំរាប់បំរើឱ្យការស្រោចស្រព។

3. បង្កើនកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន :

+ ក្នុងការប្រើប្រាស់មធ្យោបាយ សំភារៈ ឧបករណ៍បូមបាច ជាពិសេសម៉ាស៊ីនបូមទឹកដែលមាននៅមូលដ្ឋានស្រាប់សំរាប់អន្តរាគមន៍ពេលជួបគ្រោះរាំងស្ងួត ។

+ ទប់ស្កាត់ឱ្យខាងតែបាន នូវរាល់សកម្មភាពជនទាំងឡាយណា ដែលបង្កឱ្យមានការខូចខាតដល់សំណង់ធារាសាស្ត្រ ដូចជាការកាប់ភ្លឺស្រែ ប្រឡាយ ឬគាស់បង្ហើបទ្វារទឹកដើម្បីដាក់ឧបករណ៍នេសាទ និងសកម្មភាពផ្សេងៗទៀតធ្វើឱ្យរាំងស្ទះដល់ការងារបង្កបង្កើនផល ។

4. រៀបចំឱ្យបានល្អនូវកិច្ចដំណើរការ និងការថែទាំសំណង់ធារាសាស្ត្រ ដើម្បីឈានទៅបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ។

ទទួលបានសារាចរណែនាំនេះ គ្រប់មន្ទីរធនធានទឹក និងឧតុនិយមខេត្ត-ក្រុង ត្រូវខិតខំអនុវត្តតាមខ្លឹមសារខាងលើឱ្យបានលទ្ធផលល្អប្រកបដោយភាពម្ចាស់ប្រឌិត និងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី 16 ខែ 11 ឆ្នាំ២០០១

រដ្ឋមន្ត្រី

លឹម គានហោ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្ត-ក្រុង
- នាយកដ្ឋានក្រោមឱវាទក្រសួង

" ដើម្បីជូនជ្រាប "

- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ក្រសួងអប់រំ យុវជន និង កីឡា

លេខ.....៥៤៧.....អយក.ប្រក

# ប្រ កា ស

*******

ស្តីពីការប្តូរឈ្មោះវិទ្យាល័យ « ស្រុកបាត់ដំបង » ទៅជាវិទ្យាល័យ « ថ្មគោល »

ស្ថិតនៅក្នុងស្រុក ថ្មគោល ខេត្ត បាត់ដំបង ។

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា។
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២។
- យោងលិខិតស្នើសុំរបស់គណៈកម្មការទ្រទ្រង់វិទ្យាល័យ លេខ ០០៧ គក.ទ្រ_វិសប ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០១ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និងអភិបាលខេត្តបាត់ដំបង ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

## សំ រេ ច

**ប្រការ ១ :** អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យ « ស្រុកបាត់ដំបង » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ថ្មគោល » ចាប់ពីឆ្នាំសិក្សា ២០០១_២០០២ តទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជននិងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ ២០០១

ស.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

ឌឹម_សិទ្ធិ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពតិមាន "
- សាលាខេត្តបាត់ដំបង " ដើម្បីជាពតិមាន "
- ដូចប្រការ ៣
- កាលប្បវត្តិ_ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ.....៨០៨.......អយក.ប្រក

# ប្រ កា ស

*******

ស្តីពីការពង្រីកអនុវិទ្យាល័យ

«សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ មហាលាភ» ទៅជាវិទ្យាល័យ «សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ មហាលាភ»

ស្ថិតនៅក្នុងឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា។
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២។
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម លេខ ៤៨៦ អយក.កច.មស ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០១ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តកំពង់ចាម ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

# សំ រេ ច

**ប្រការ ១ :** អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ មហាលាភ »បច្ចុប្បន្នទៅជាវិទ្យាល័យ « សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ មហាលាភ » ចាប់ពីឆ្នាំសិក្សា ២០០១_២០០២ តទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ។

**ប្រការ ៣ :** នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជនកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០០១

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពង់ចាម " ដើម្បីជាពត៌មាន "
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ ឌ.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

ក្រសួងអប់រំ យុវជន និង កីឡា

លេខ......៩៨១៩......អយក.ប្រក

# ប្រ កា ស

*******

ស្តីពីការពង្រីក អនុវិទ្យាល័យ « តាមាង » ទៅជាវិទ្យាល័យ « តាមាង »

ស្ថិតនៅក្នុងឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា។
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០៦ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២។
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំកោះរកា ក្នុងស្រុកកំពង់សៀម ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០០ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ចាម ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

## ស ំ រេ ច

**ប្រការ ១ :** អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « តាមាង » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « តាមាង » ចាប់ពីឆ្នាំសិក្សា ២០០១_២០០២ នេះតទៅ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជននិងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម និងនាយកវិទ្យាល័យសាមី ហនភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០០១

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តកំពង់ចាម "ដើម្បីជាពត៌មាន"
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ ឆា.មចទ

C. New school Increase 2.doc

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ៣០៥ សកបយ

ភ្នំពេញ ថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ ២០០១

**ប្រកាស**

**ស្តីពី**

**ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករ និយោជិត**
**នៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជា**
**សមូហភាពដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន**

***រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា***

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/កប ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**សំរេច**

**ប្រការ ១.-** ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករ និយោជិត ត្រូវបានទទួលស្គាល់ក្នុងក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈ ដូចខាងក្រោមនេះ :

-ក្នុងក្របខណ្ឌភូមិសាស្ត្រ

-នៅថ្នាក់សហគ្រាស ឬគ្រឹះស្ថាន

-នៅថ្នាក់ខេត្ត ឬក្រុង

-នៅថ្នាក់ជាតិ ។

-ក្នុងក្របខ័ណ្ឌវិជ្ជាជីវៈ

-វិជ្ជាជីវៈមួយជាក់លាក់

-វិជ្ជាជីវៈច្រើនបញ្ចូលរួមគ្នា ឬប្រហាក់ប្រហែលគ្នា

-សកម្មភាពសេដ្ឋកិច្ចមួយ ឬផ្នែកមួយនៃសកម្មភាពសេដ្ឋកិច្ចមួយជាកំណត់

-សកម្មភាពសេដ្ឋកិច្ចច្រើន ឬផ្នែកច្រើននៃសកម្មភាពសេដ្ឋកិច្ច ។

**ប្រការ ២.-** សហជីពថ្នាក់សហគ្រាស ឬគ្រឹះស្ថានត្រូវចុះបញ្ជិកានៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្របតាមប្រកាសលេខ ២៧៧ សកបយ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០០ ។

**ប្រការ ៣.-** លក្ខន្តិកៈសហជីពត្រូវកំណត់ថាតើសហជីពនេះមានគោលបំណងតំណាងឱ្យកម្មករ និយោជិតទាំងអស់របស់សហគ្រាស គ្រឹះស្ថាន ឬគ្រាន់តែតំណាងឱ្យប្រភេទមួយ ឬច្រើនដែលកំណត់ដោយលក្ខន្តិកៈ ។ ក្នុងករណីនេះគឺមានតែកម្មករ និយោជិត ដែលស្ថិតក្នុងប្រភេទនោះ ឬប្រភេទទាំងឡាយនោះទេដែលអាចចូលជាសមាជិកសហជីព ។ ត្រូវហាមឃាត់មិនអោយបង្កើតសហជីព ឬសមាគមទាំងឡាយដែលរួមបញ្ចូលនិយោជកនិងកម្មករនិយោជិត នៅក្នុងសហជីព ឬសមាគមតែមួយជាមួយគ្នា ។

លក្ខន្តិកៈសហជីពត្រូវកំណត់លក្ខខណ្ឌសំរាប់ជ្រើសរើសអ្នកដឹកនាំរបស់ខ្លួនតាមរយៈការបោះឆ្នោត ជាសម្ងាត់ ។ ទោះជាយ៉ាងនេះក្តី អាណត្តិរបស់អ្នកដឹកនាំមិនត្រូវលើសពីពីរឆ្នាំឡើយ ប៉ុន្តែគេអាចត្រូវបានបោះឆ្នោតជ្រើសរើសជាថ្មីបាន ។

កម្មករ និយោជិត ទាំងអស់ដែលជាបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពទទួលបាននូវការការពារចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេល៤៥ថ្ងៃមុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ថ្ងៃក្រោយការបោះឆ្នោតប្រសិនបើបេក្ខជនទាំងនេះមិនត្រូវបានជាប់ឆ្នោត ។ សហជីពត្រូវជូនដំណើងទៅនិយោជកអំពីបេក្ខភាពនេះតាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ ។ និយោជកត្រូវអនុវត្តបទបញ្ញត្តិនេះតែម្តងគត់នៅរៀងរាល់ពេលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ។

អាណត្តិនៃអ្នកដឹកនាំសហជីពថ្នាក់សហគ្រាស គ្រឹះស្ថាននឹងត្រូវបញ្ចប់ដោយសារការបញ្ចប់នៃកិច្ចសន្យាការងារតែក្នុងករណីដែលបញ្ហានេះបានចែងក្នុងលក្ខន្តិកៈសហជីព ។

អ្នកដឹកនាំសហជីពទាំងអស់ដែលត្រូវបានបញ្ឈប់ជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ដោយហេតុផលសេដ្ឋកិច្ច ឬហេតុផលផ្សេងៗទៀត នៅតែមានសិទ្ធិចេញចូលក្នុងសហគ្រាស ដើម្បីបំពេញភារៈទទួលខុសត្រូវស្របតាមអាណត្តិសហជីពរបស់ខ្លួន។ ថ្នាក់ដឹកនាំសហជីពណាម្នាក់ដែលបានប្រព្រឹត្តខុស ហើយត្រូវបានបណ្តេញចេញស្រេចច្បាប់ត្រូវតែលាលែងពីសហជីព ។

**ប្រការ ៤.-** ចាប់តាំងពីពេលដាក់ពាក្យសុំចុះបញ្ជិកាសហជីព កម្មករ និយោជិតទាំងអស់ដែលជាស្ថាបនិក ឬកម្មករ និយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះក្នុងពេលកំពុងស្នើសុំចុះបញ្ជិកាត្រូវបានការការពារដូចគ្នានិងប្រតិភូបុគ្គលិកដែរ។ ការការពារនេះមានរយៈពេលរហូតដល់ ៣០ ថ្ងៃក្រោយកាលបរិច្ឆេទនៃការចុះបញ្ជិកាសហជីព។

ផុតរយៈពេលកំណត់ក្នុងកថាខ័ណ្ឌខាងលើ ការការពារនេះត្រូវបានផ្តល់អោយអ្នកដឹកនាំសហជីព ៣ នាក់ក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៨២ និង ២៩៣ នៃច្បាប់ស្តីពីការងារ។ ចំពោះសហជីពដែលមានសមាជិកលើសពី ២១០ នាក់ ការការពារនេះត្រូវផ្តល់អោយសមាជិកសហជីពម្នាក់សំរាប់ភាគបន្ថែមនីមួយៗដែលមានសមាជិកសហជីព ២០០ នាក់។ ការការពារនេះ អាចផ្តល់កាន់តែច្រើនថែមទៀតដោយអនុសញ្ញារួម។ ដើម្បីទទួលបាននូវការការពារនេះសហជីពត្រូវជូនដំណឹងដល់និយោជកអំពីឈ្មោះអ្នកដែលត្រូវទទួលការការពាតាមគ្រប់មធ្យោបាយដែលទុកជាបានការ។ សេចក្តីចម្លងមួយច្បាប់នៃការជូនដំណឹងនេះត្រូវផ្ញើទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

ក្នុងករណីដែលមានការតវ៉ាអំពីចំនួនសមាជិកសហជីព ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងធ្វើការអង្កេត។ ក្នុងករណីនេះ ភាគីដែលមានការពាក់ព័ន្ធជាពិសេសភាគីដែលជាកម្មវត្ថុនៃការអង្កេតត្រូវផ្តល់ជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នូវភស្តុតាងទាំងអស់ដែលបញ្ជាក់អំពីភាពដ៏ត្រឹមត្រូវរបស់ខ្លួន។

និយោជកណាដែលបញ្ឈប់ឬ បណ្តេញកម្មករ និយោជិត ពីការងារដែលបានទទួលការការពារស្របតាមបទបញ្ញត្តិទាំងឡាយខាងលើដោយគ្មានការអនុញ្ញាតជាមុនពីអធិការការងារ ឬក៏ធ្វើអោយមានការខូចខាតណាមួយដល់កម្មករ និយោជិតនោះ ត្រូវទទួលពិន័យស្របតាមមាត្រា ៣៧៣ នៃច្បាប់ស្តីពីការងារ។ វិធានការទាំងឡាយ របស់និយោជកដែលរំលោភលើបទបញ្ញត្តិខាងលើនេះ ត្រូវចាត់ទុកជាមោឃៈនិងគ្មានតំលៃអ្វីទាំងអស់។ ក្រសួងនិងចាត់វិធានការទាំងអស់នៅក្នុងសមត្ថកិច្ចរបស់ខ្លួនយ៉ាងម៉ឺងម៉ាត់ជាបន្ទាន់ដើម្បីអោយកម្មករនិយោជិតដែលត្រូវបានបណ្តេញចេញពីការងារអោយបានចូលធ្វើការវិញ( ទោះបីជារឿងក្តីនេះកំពុងរង់ចាំការជំនុំជំរះនៅចំពោះមុខតុលាការមានសមត្ថកិច្ចក៏ដោយ) ។ វិធានការទាំងអស់នេះ រួមមានកិច្ច

សហប្រតិបត្តិការជាមួយក្រសួងដទៃទៀតដូចមានចែងក្នុងប្រកាសអន្តរក្រសួង លេខ ២៥៨៨ ពណ បអព ប្រក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០០ ។

**ប្រការ ៥.-** សហជីពទាំងអស់ដែលបានបង្កើតឡើងនៅថ្នាក់សហគ្រាស គ្រឹះស្ថានស្របតាមមាត្រា ២៦៨ នៃច្បាប់ស្តីពីការងារមានសិទ្ធិតំណាងអោយផលប្រយោជន៍របស់សមាជិករបស់ខ្លួនតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីការងារ ។

សិទ្ធិដូចគ្នានេះត្រូវបានផ្តល់អោយសហជីពថ្នាក់ខ្ពស់ជាងសហគ្រាស គ្រឹះស្ថាន( ឧទាហរណ៍: សហជីពដែលបង្កើតឡើងតាមសកម្មភាពសេដ្ឋកិច្ចមួយឬតាមផ្នែកមួយនៃសកម្មភាពសេដ្ឋកិច្ច ឬសហជីពថ្នាក់ជាតិ) ប្រសិនបើសហជីពថ្នាក់ខ្ពស់ទាំងនោះមានសមាជិករបស់ខ្លួននៅក្នុងសហគ្រាសឬគ្រឹះស្ថាននោះ ។ សហជីពទាំងនេះអាចចាត់តាំងតំណាងសហជីពម្នាក់នៅថ្នាក់សហគ្រាស គ្រឹះស្ថាន ចំនួនតំណាងសហជីពអាចច្រើនជាងនេះ ដោយការចរចាជាសមូហភាព ។

តំណាងសហជីពដែលត្រូវបានចាត់តាំងស្របតាមកថាខ័ណ្ឌខាងលើ នឹងទទួលបាននូវការការពារដូចមានចែងក្នុងមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ ។

សហជីពទាំងអស់ដែលបង្កើតឡើងក្នុងសហគ្រាសគ្រឹះស្ថានត្រូវតែផ្តល់ភស្តុតាងនៃភាពជាតំណាងរបស់ខ្លួន ។ភស្តុតាងនេះត្រូវយកតាមលក្ខណៈវិនិច្ឆ័យទាំងឡាយដែលមានចែងក្នុងមាត្រា ២៧៧ នៃច្បាប់ស្តីពីការងារ ។

កម្មករ និយោជិតទាំងអស់ដែលជាសមាជិកសហជីពអាចស្នើសុំជាលាយលក្ខណ៍អក្សរក្នុងរយៈពេលយ៉ាងតិច១៥ថ្ងៃមុន ដើម្បីអោយនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួនដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិកស្របតាមមាត្រា ១២៩ នៃច្បាប់ស្តីពីការងារ ហើយនិយោជកត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវតាមសំណើនេះ ។ តាមសំណើរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះ បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និយោជកត្រូវផ្តល់សេចក្តីបញ្ជាក់របស់ខ្លួនអំពីចំនួនកម្មករនិយោជិតដែលបានស្នើសុំកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហជីព ប្រភេទនិងឈ្មោះសហជីពឬសហជីពទាំងឡាយដែលបានទទួលផលពីនីតិវិធីនេះ ។ សេចក្តីបញ្ជាក់នេះគឺជាភស្តុតាងបន្ថែមដើម្បីកំណត់ភាពជាតំណាងរបស់សហជីព ។

**ប្រការ ៦.-** សហជីពណាដែលសមាជិករបស់ខ្លួនមានចំនួនភាគច្រើនដាច់ខាតនៃចំនួនកម្មករ និយោជិតទាំងអស់ក្នុងសហគ្រាស គ្រឹះស្ថាន សហជីពនោះមានសិទ្ធិតំណាងអោយកម្មករ និយោជិតទាំងមូលនៃសហគ្រាសគ្រឹះស្ថាននោះ ។សហជីពណាដែលសមាជិករបស់ខ្លួនមានចំនួនភាគច្រើនដាច់ខាតនៃចំនួនកម្មករ និយោជិតប្រភេទណាមួយជាក់លាក់នៅក្នុងសហគ្រាស គ្រឹះស្ថាន សហជីពនោះមានសិទ្ធិតំណាង អោយតែកម្មករ

និយោជិតនៃប្រភេទនោះតែប៉ុណ្ណោះ។ ក្នុងករណីផ្ទុយពីនេះ សហជីពនីមួយៗមានសិទ្ធិតំណាងអោយតែសមាជិករបស់ខ្លួនតែប៉ុណ្ណោះ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បញ្ជាក់អំពីភាពជាតំណាងបំផុតនៃសហជីពតាមសេចក្តីស្នើសុំរបស់សហជីពនោះ ដែលសហជីពនោះត្រូវផ្តល់ជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នូវគ្រប់ភស្តុតាងដ៏សមស្របទាំងឡាយ ពិសេសភស្តុតាងដូចមានចែងក្នុងមាត្រា ២៧៧ នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែមុននឹងផ្តល់សេចក្តីបញ្ជាក់នេះក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្នើអោយនិយោជកនិងសហជីពដែលជាសមាជិកគណៈកម្មការប្រឹក្សាការងារផ្តល់នូវសេចក្តីសង្កេតរបស់ខ្លួន ឬសេចក្តីជំទាស់ដោយថាហេតុរបស់ខ្លួនក្នុង រយៈពេល ១៥ថ្ងៃគត់។ សេចក្តីស្នើនេះត្រូវធ្វើតាមរយៈសំបុត្រអនុសិដ្ឋឬលិខិតជូនផ្ទាល់ដៃដែលមានចុះហត្ថលេខាថាបានទទួលហើយ។ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានការពាក់ព័ន្ធក៏អាចផ្តល់នូវសេចក្តីសង្កេតរបស់ខ្លួន ឬសេចក្តីជំទាស់ដោយថាហេតុក្នុងរយៈពេលដូចគ្នានេះដែរ។ ផុតកំណត់ពេលនេះប្រសិនបើគ្មានសេចក្តីជំទាស់ណាមួយទេ ទើបក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចចេញសេចក្តីបញ្ជាក់នេះបាន។

ករណីក្រសួងសំរេចមិនបញ្ជាក់អំពីភាពជាតំណាងបំផុតរបស់សហជីព សហជីពអាចស្នើអោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រៀបចំការបោះឆ្នោតជាសម្ងាត់ដោយមានការចូលរួមរបស់កម្មករ និយោជិត ឬប្រភេទ កម្មករ និយោជិតទាំងអស់ដែលសហជីពនោះតំណាងក្នុងលក្ខខណ្ឌដូចមានចែងក្នុងបទបញ្ញត្តិនៃកថាខ័ណ្ឌ ២ នៃប្រការ ៧ ខាងក្រោម ។ ប្រសិនបើមានសហជីពច្រើនបានបង្ហាញភស្តុតាងជូនក្រសួងថា សហជីពទាំងនោះជាតំណាងកម្មករ និយោជិត នៅក្នុងសហគ្រាស គ្រឹះស្ថាន សហជីពទាំងនោះត្រូវតែបានចូលរួមក្នុងការបោះឆ្នោត ។ សហជីពដែលទទួលបានសម្លេងភាគច្រើននៃសន្លឹកឆ្នោតបានការក្នុងពេលបោះឆ្នោតត្រូវបានទទួលស្គាល់ថា ជាសហជីពដែលមានភាពជាតំណាងបំផុត ។ ប្រសិនបើសហជីពណាមួយមិនបានទទួលសម្លេងភាគច្រើននៃសន្លឹកឆ្នោតបានការក្នុងពេលបោះឆ្នោតសហជីពនោះត្រូវបានទទួលស្គាល់ថា ជាសហជីពមានសមាជិកភាគតិច។

សហជីពត្រូវបានទទួលស្គាល់ថាជាសហជីពដែលមានភាពជាតំណាងបំផុតក្នុងរយៈពេល ២ឆ្នាំ ជាអប្បបរមា។ ផុតរយៈពេលនេះ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានការពាក់ព័ន្ធអាចស្នើ សុំអោយរៀបចំការបោះឆ្នោតជាថ្មីក្នុងគោលបំណងបញ្ជាក់ថា សហជីពនេះនៅតែរក្សាបាននូវភាពជាតំណាងបំផុតរបស់ខ្លួន។

**ប្រការ ៧ :-** កាលបរិច្ឆេទ និងទីកន្លែងបោះឆ្នោតត្រូវជូនដំណឹងដល់កម្មករ និយោជិតយ៉ាងតិចប្រាំពីរថ្ងៃគត់មុនការបោះឆ្នោត។ និយោជកត្រូវអនុញ្ញាតអោយមន្ត្រីដែលចាត់តាំងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះ

បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ផ្តល់ដល់កម្មករ និយោជិតនូវពត៌មានទាំងឡាយដែលចាំបាច់សំរាប់ការបោះឆ្នោត។ មន្ត្រីនេះត្រូវជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ ដូចមានចែងក្នុងកថាខ័ណ្ឌ ២នៃប្រការ ៧ នេះដើម្បីកម្មករ និយោជិតទាំងនោះអាចចូលរួមក្នុងការបោះឆ្នោត។ មន្ត្រីដែលបានទទួលការចាត់តាំងពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ធ្វើការសំរុះសំរួលទាំងឡាយជាក់ស្តែងដើម្បីឱ្យការបោះឆ្នោតអាចប្រព្រឹត្តទៅបានដោយពិគ្រោះយោបល់ជាមួយនិយោជក និងសហជីពអំពីពេលម៉ោងបោះឆ្នោត ការិយាល័យបោះឆ្នោតជាដើម។

កម្មករ និយោជិតទាំងអស់ដែលធ្វើការជាទៀងទាត់នៅក្នុងសហគ្រាស គ្រឹះស្ថានយ៉ាងតិចបីខែ ដោយគិតចាប់ពីថ្ងៃចូលសាកល្បងការងារ មានសិទ្ធិចូលរួមក្នុងការបោះឆ្នោត។ ប្រសិនបើសហជីពតំណាងអោយតែប្រភេទមួយជាកំណត់នៃកម្មករ និយោជិត គឺមានតែកម្មករ និយោជិត ដែលស្ថិតក្នុងប្រភេទ នេះទេដែលអាចចូលរួមក្នុងការបោះឆ្នោតនេះបាន។

សហជីពអាចធ្វើយុទ្ធនាការផ្តល់ពត៌មានចាំបាច់ទាំងអស់សំរាប់ការបោះឆ្នោត ដូចជាអំពីកាលបរិច្ឆេទ ទីកន្លែងនៃការបោះឆ្នោត ទំរង់សន្លឹកឆ្នោត នីតិវិធីនៃការបោះឆ្នោតជាដើម។ ការធ្វើយុទ្ធនាការនេះត្រូវប្រព្រឹត្តទៅនៅក្រៅពេលម៉ោងធ្វើការ ឬក្នុងម៉ោងធ្វើការនៅក្នុងសហគ្រាស គ្រឹះស្ថាន ប្រសិនបើមានការយល់ព្រមពីនិយោជក និង ស្របតាមបែបបទដែលនិយោជកបានយល់ព្រម។

សន្លឹកឆ្នោតត្រូវរៀបចំយ៉ាងណាកុំអោយមានការច្រឡំ។ បើអាចធ្វើទៅបានសន្លឹកឆ្នោតមានតែសំនួរមួយគត់ដែលមានប្រអប់សំរាប់គូស (ឧទាហរណ៍ តើអ្នកចង់អោយសហជីព "ក" តំណាងអោយអ្នកឬទេ? ដោយមានប្រអប់សំរាប់គូសថាបាទ ចាំ ឬទេ)។ ក្នុងករណីមានឈ្មោះសហជីពច្រើននៅក្នុងសន្លឹកឆ្នោតត្រូវមានប្រអប់សំរាប់គូសនៅជាប់និងឈ្មោះសហជីពនីមួយៗ នៃសន្លឹកឆ្នោតនោះ។ ជាអាទិ៍សន្លឹកឆ្នោតអាចដាក់រូបថត នៃអ្នកដឹកនាំសហជីព ឬសហជីពទាំងឡាយ ដោយមានឈ្មោះរបស់សហជីព និងដោយមានប្រអប់សំរាប់គូសនៅជិតរូបថត គឺធ្វើយ៉ាងនេះដើម្បីជួយ កម្មករ និយោជិត ដែលមិនអាចអានអក្សរបានធ្វើការជ្រើសរើស។

ការបោះឆ្នោតត្រូវធ្វើក្នុងពេលម៉ោងធ្វើការ ប្រសិនបើមានការយល់ព្រមពីនិយោជក។ ការបោះឆ្នោតត្រូវធ្វើនៅមុន ឬក្រោយពេលម៉ោងធ្វើការភ្លាមៗ ប្រសិនបើគ្មានការយល់ព្រមពីនិយោជកអោយធ្វើការបោះឆ្នោតក្នុងពេលម៉ោងធ្វើការទេ។

ការបោះឆ្នោតត្រូវធ្វើនៅកន្លែងធ្វើការប្រសិនបើមានការយល់ព្រមពីនិយោជក ឬនៅទីណា ជិតកន្លែងធ្វើការប្រសិនបើគ្មានការយល់ព្រមពីនិយោជកទេ។

ការបោះឆ្នោតត្រូវស្ថិតក្រោមអធិបតីភាពនៃមន្ត្រីដែលតែងតាំងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។ មន្ត្រីនេះនឹងចាត់តាំងមនុស្សម្នាក់ ឬច្រើននាក់ផងដែរ ដើម្បីពិនិត្យ

មើលភាពត្រឹមត្រូវនៃការបោះឆ្នោត។ តំណាងសហព័ន្ធសហជីពថ្នាក់ជាតិ អង្គការជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធមានសិទ្ធិចូលរួមសង្កេតការណ៍ ដើម្បីពិនិត្យមើលភាពត្រឹមត្រូវនៃការបោះឆ្នោត។

សហជីពទាំងអស់ដែលយកចិត្តទុកដាក់ចំពោះលទ្ធផលនៃការបោះឆ្នោត មានសិទ្ធិចាត់តាំងអ្នកជំនួយការពិនិត្យសន្លឹកឆ្នោតម្នាក់ ឬច្រើននាក់ ដើម្បីជួយមន្ត្រីដែលតែងតាំងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្នុងការរាប់សន្លឹកឆ្នោត។

ដោយមានការព្រមព្រៀងពីភាគីទាំងអស់ដែលពាក់ព័ន្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចប្រគល់ការរៀបចំ និងការត្រួតពិនិត្យការបោះឆ្នោតជូនតតិយជន ឬស្ថាប័នសាធារណៈ ឬឯកជនដែលទទួលបាន ទំនុកចិត្តក្នុងការបំពេញកិច្ចការនេះ។

ត្រូវធ្វើការរាប់សន្លឹកឆ្នោតជាសាធារណៈ បន្ទាប់ពីការបោះឆ្នោតត្រូវបានបញ្ចប់ភ្លាម។ លទ្ធផលត្រូវប្រកាសដោយជនដែលទទួលបន្ទុកត្រួតពិនិត្យសន្លឹកឆ្នោត បន្ទាប់ពីការរាប់សន្លឹកឆ្នោតបានបញ្ចប់។

សហជីពដែលត្រូវបានទទួលស្គាល់ថា ជាសហជីពដែលមានភាពជាតំណាងបំផុតឆ្លងតាមការបោះឆ្នោត នេះ ទទួលបាននូវភាពជាតំណាងនេះ បន្ទាប់ពីលទ្ធផលនៃការបោះឆ្នោតត្រូវបានប្រកាសស្របតាមកថាខ័ណ្ឌខាងលើ។

រាល់ការធ្វើឧបាស្រ័យទាក់ទងដល់ភាពត្រឹមត្រូវនៃការបោះឆ្នោត ឬលទ្ធផលនៃការបោះឆ្នោត ត្រូវតែដាក់ជូនតុលាការមានសមត្ថកិច្ចក្នុងរយៈពេលប្រាំបីថ្ងៃគត់ដោយគិតចាប់ពីថ្ងៃប្រកាសលទ្ធផល។ ការធ្វើឧបាស្រ័យនេះមិនមានផលធ្វើអោយផ្អាកការអនុវត្តន៏លទ្ធផលនៃការបោះឆ្នោតឡើយ។

**ប្រការ ៨.-** ដោយមិនគិតដល់បទបញ្ញត្តិទាំងឡាយនៃកថាខ័ណ្ឌ១ នៃប្រការ ៦ ខាងលើ សហជីពមានសមាជិកភាគតិចមានសិទ្ធិតំណាងអោយតែសមាជិករបស់ខ្លួនតែប៉ុណ្ណោះ។

សហជីពមានសមាជិកភាគតិច ក៏អាចចូលរួមក្នុងការតាក់តែងសេចក្តីព្រាងអនុសញ្ញារួមផងដែរ ប្រសិនបើសហជីពមានភាពជាតំណាង ឬតំណាងបំផុតអញ្ជើញអោយចូលរួម។

**ប្រការ ៩.-** សហជីពដែលមានភាពជាតំណាងបំផុតមានសិទ្ធិស្នើសុំអោយនិយោជកធ្វើការចរចាអំពីអនុសញ្ញារួមដែលអនុវត្តចំពោះកម្មករ និយោជិតទាំងអស់ ដែលសហជីពនោះតំណាងអោយ។ ក្នុងករណីនេះ និយោជកមានកាតព្វកិច្ចត្រូវតែធ្វើការចរចាជាមួយសហជីព។

នៅក្នុងសហគ្រាស គ្រឹះស្ថានណាដែលពុំទាន់មានសហជីពមានភាពជាតំណាងបំផុតនោះសហជីពទាំងអស់ ឬសហជីពច្រើន ដែលមានសមាជិកនៅក្នុងសហគ្រាស គ្រឹះស្ថាននោះអាចរួបរួមគ្នាដើម្បីលើកឡើងនូវសេចក្តីព្រាងរួមនៃអនុសញ្ញារួម។ និយោជកមានកាតព្វកិច្ចត្រូវធ្វើការចរចា ប្រសិនបើសហជីពទាំង

នោះតំណាងអោយកម្មករ និយោជិតភាគច្រើននៃសហគ្រាស គ្រឹះស្ថាន ឬប្រភេទកម្មករ និយោជិតដែលអនុសញ្ញារួមនោះគ្របដណ្តប់។ ក្នុងករណីមានការតវ៉ាអំពីភាពជាតំណាងអោយកម្មករ និយោជិតភាគច្រើននៃសហគ្រាស គ្រឹះស្ថាន ការបោះឆ្នោតស្របតាមវិធាន ដែលមានចែងក្នុងប្រការ ៦ ខាងលើត្រូវតែយកមកអនុវត្ត។

ក្នុងករណីដែលសហជីពមានសមាជិកភាគតិចទាំងអស់រួមគ្នាទៅ មិនតំណាងឱ្យកម្មករ និយោជិតភាគច្រើននៅក្នុងសហគ្រាស គ្រឹះស្ថាន ឬប្រភេទនៃកម្មករ និយោជិត ដែលគ្របដណ្តប់ដោយអនុសញ្ញារួមនៃការងារនោះទេ និយោជកត្រូវមានកាតព្វកិច្ចធ្វើការចរចាជាមួយសហជីពទាំងនោះក្នុងនាមសមាជិកដែលសហជីពទាំងនោះតំណាងឱ្យតែប៉ុណ្ណោះ។

សហជីពទាំងឡាយដែលមានសិទ្ធិចរចាជាសមូហភាពជាមួយនិយោជកអាចកំណត់ដោយសេរីនូវវិធានទាំងឡាយ ដើម្បីតាក់តែងសេចក្តីព្រាងអនុសញ្ញារួម និងដើម្បីរៀបចំសមាសភាពនៃគណៈកម្មការដែលទទួលបន្ទុកធ្វើការចរចា។

ក្នុងករណីដែលសហជីពណាមួយបានទទួលសម្លេងភាគច្រើនដាច់ខាតនៃការបោះឆ្នោតខាងលើ សហជីព នោះត្រូវបានទទួលស្គាល់ជាភ្នាក់ងារផ្តាច់មុខក្នុងការចរចា ដើម្បីតំណាងអោយកម្មករ និយោជិតទាំងអស់ ដែលទាក់ទងនឹងការចរចានេះ។

**ប្រការ ១០.-** និយោជកដែលមានកាតព្វកិច្ចធ្វើការចរចាជាមួយសហជីព ត្រូវតែចូលរួមប្រជុំជាមួយតំណាងសហជីពដែលជាដៃគូ។ ក្នុងអំឡុងពេលចចារនេះ តំណាងចចារមិនត្រូវបាន កាត់ប្រាក់ឈ្នួល ប្រាក់រង្វាន់ និងផលប្រយោជន៍ផ្សេងៗឡើយ។

**ប្រការ ១១.-** កាតព្វកិច្ចរបស់គ្រប់ភាគីនៃការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមមានជាអាទិ៍:

ក-កាតព្វកិច្ចសំរបសំរួលអោយមាននីតិវិធីនៃការចរចាដែលមានលក្ខណៈរៀបរយអាចទទួលយកបាន។

ខ-កាតព្វកិច្ចធ្វើសម្បទាន និងការជំទាស់ ដោយមានការពិនិត្យពិចារណា សមហេតុសមផល។

គ-កាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់ដល់តំណាងសហជីព ឬសហជីពទាំងឡាយនូវមធ្យោបាយសំរាប់បង្កលក្ខណៈងាយស្រួលទាំងឡាយដ៏សមស្រប ដើម្បីអាចបំពេញបេសកកម្មក្នុងការចរចារបស់ខ្លួនបាន។

ឃ-កាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់នូវពត៌មានទាំងអស់ពាក់ព័ន្ធនិងការចរចា ដែលបានស្នើឡើងដោយសហជីព ដែលបានចូលរួមក្នុងដំណើរការចរចា។

**ប្រការ ១២.-** ភាគីនៃការចរចាជាសមូហភាពអាចកំណត់ដោយសេរីនូវកាលបរិច្ឆេទដែលត្រូវជួបគ្នាដើម្បីធ្វើការចរចា ។ កាលបរិច្ឆេទនេះមិនត្រូវមានថិរវេលាតិចជាង ៣០ ថ្ងៃ ប្រតិទិនឡើយ ។

ការជូនដំណឹងគ្នាទៅវិញទៅមកអំពីកម្មវត្ថុ និងកាលបរិច្ឆេទនៃការចរចាជាសមូហភាព ត្រូវធ្វើតាមសំបុត្រអនុសិដ្ឋ ឬលិខិតជូនផ្ទាល់ដៃ ដែលមានចុះហត្ថលេខាថាបានទទួលហើយ ។

ផុតកាលបរិច្ឆេទដែលបានកំណត់ដំបូង ភាគីនៃការចរចាជាសមូហភាពអាចកំណត់កាលបរិច្ឆេទនេះជាថ្មីតាមបំណងរបស់ខ្លួន ប្រសិនបើគេមិនសំរេចបិទការចរចាគ្នាទេនោះ ។ ក្នុងករណីនេះ មុននឹងធ្វើកូដកម្ម ឬឡុកអៅ បណ្តាភាគីត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងជំពូកទី ១២ ស្តីពីការដោះស្រាយវិវាទការងារ និងជំពូកទី ១៣ ស្តីពីកូដកម្ម-ឡុកអៅ នៃច្បាប់ស្តីពីការងារ ។

**ប្រការ ១៣ :-** អនុសញ្ញារួមដែលបានធ្វើនៅថ្នាក់សហគ្រាស គ្រឹះស្ថានមានអានុភាពដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់ស្តីពីការងារ ។

**ប្រការ ១៤ :-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>ចម្លងជូន:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង "ដើម្បីជ្រាប"
-អគ្គនាយកដ្ឋានរដ្ឋបាលរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
"ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"
-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក "ដើម្បីអនុវត្ត"
-សហព័ន្ធសហជីព "ដើម្បីអនុវត្ត"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-ឯកសារ
-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ៜៜ

ក្រសួងធម្មការ និង សាសនា

លេខ...៧៥៥.........ក.ធ.ស ៗ

## ប្រកាសស្តីពីបើក

នៃ

## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃ " ព្រះសហគមន៍កាតូលិក " នៅខេត្តកណ្តាលរបស់លោកស្រី ម៉ឺន អេង ភេទស្រី អាយុ៥៦ ឆ្នាំ. ចុះថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០០១
- យោងចំណារបញ្ជូនរបស់សាលាខេត្តកណ្តាល លេខៈ៣០០សណ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ២០០១

## ស ម្រេ ច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " គ្រួគ្រីសន្តិភាព " មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " គ្រួគ្រីសន្តិភាព " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

<u>ប្រការ៣</u>: បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **ក្សត្រីសន្តិភាព** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនានិង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

<u>ប្រការ៤</u>: រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជា ធរមាន ។

<u>ប្រការ៥</u>: ខុទ្ទកាល័យ - នាយកដ្ឋានរដ្ឋបាល - អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពហុសាសនា** " គ្រប់ស្ថាប័ន - អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះឱ្យ មានប្រសិទ្ធិភាពខ្ពស់ ។

<u>ប្រការ៦</u>: សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

រដ្ឋមន្ត្រី

**ជា-សាវឿន**

**<u>ចម្លងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

" <u>ដើម្បីគោរពជូនជ្រាប</u> "

- រាជកិច្ច ( <u>ដើម្បីចុះផ្សាយ</u> )
- សាលាខេត្តកណ្តាល
- មន្ទីរធម្មការ និងសាសនា ខេត្តកណ្តាល
- សាខាស្នាក់ការ " **ក្សត្រីសន្តិភាព** "

" <u>ដើម្បីអនុវត្ត</u> "

- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ...៣៦៣.........ក.ធ.ស ៣ម

## សេចក្ដីសំរេច

## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនៃក្រុមប្រឹក្សា **"សេចក្ដីសង្គ្រោះនៅក្នុងព្រះគ្រីស្ទ"** នៅខេត្តសៀមរាប របស់លោក **ឈឹម សុខា** ភេទប្រុស អាយុ ២៤ ឆ្នាំ. ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០
- យោងចំណារបញ្ជូនរបស់សាលាខេត្តសៀមរាបលេខ:១៧៩៦៦ខសរ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០០

## សំរេច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ **"សេចក្ដីសង្គ្រោះនៅក្នុងព្រះគ្រីស្ទព្រះគោថ្មី"** មួយកន្លែងដែលមានទីតាំងស្ថិតនៅ ក្រុមទី១ ភូមិព្រះគោថ្មី ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត **"សេចក្ដីសង្គ្រោះនៅក្នុងព្រះគ្រីស្ទព្រះគោថ្មី"** ត្រូវអនុញ្ញាតឱ្យប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត "**សេវេនដេយអាត់វេនទីស្ទព្រះគោថ្មី**" ត្រូវគោរពនិងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនានិងសណ្ដាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្ដីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ - នាយកដ្ឋានរដ្ឋបាល - អគ្គនាយកដ្ឋានធម្មការ "**នាយកដ្ឋានពាហិរសាសនា**" គ្រប់ស្ថាប័ន - អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍សេចក្ដីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្ដីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០១

ជា_សាវឿន

**ចម្លងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

"ដើម្បីគោរពជូនជ្រាប"

- រាជកិច្ច ( ដើម្បីចុះផ្សាយ )
- សាលាខេត្តសៀមរាប
- មន្ទីរធម្មការ និងសាសនា ខេត្តសៀមរាប
- សាខាស្នាក់ការ "**សេវេនដេយអាត់វេនទីស្ទព្រះគោថ្មី**"

"ដើម្បីមុខការ"

- ឯកសារ.កាលប្បវត្តិ